# តារាងសង្ខេបអំពីកាតព្វកិច្ចគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ

# សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

| **កាតព្វកិច្ច** | **ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត (មាត្រា/លេខ)** | **ឯកសារយោងនិងការបរិច្ឆេទ** |
|---|---|---|
| ១. កាតព្វកិច្ចកាន់បញ្ជីគណនេយ្យ<br>១.១. បញ្ជីគណនេយ្យ មានជាអាទិ៍៖<br>– បញ្ជី/ សៀវភៅទិញ<br>– បញ្ជី/ សៀវភៅលក់<br>– បញ្ជី/ សៀវភៅទទួលប្រាក់<br>– បញ្ជី/ សៀវភៅបង់ប្រាក់<br>– បញ្ជី/ សៀវភៅចាំបាច់ផ្សេងទៀត<br>១.២. ភាសា៖<br>សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ អាចប្រើភាសាអង់គ្លេស៖<br>– ប្រព័ន្ធគណនេយ្យកុំព្យូទ័រ និងប្រព័ន្ធកុំព្យូទ័រ ពាក់ព័ន្ធសម្រាប់ការកត់ត្រាប្រតិបត្តិការគណនេយ្យជា ភាសាអង់គ្លេស។<br>ឧទាហរណ៍ : QuickBooks, Peachtree ,Simply Accounting ជាដើម។<br>– ត្រូវជូនដំណឹងពីការប្រើប្រាស់ភាសាអង់គ្លេសមក ន.គ.ស.<br>– សហគ្រាសដែលបានចុះបញ្ជីជាផ្លូវការរួចរាល់ ត្រូវជូនដំណឹង មក ន.គ.ស. ត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២២។ | មាត្រា ២០,២១,២២ | • ព្រះរាជក្រមលេខ នស/០៩១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម |

| | | |
|---|---|---|
| – សហគ្រាសទើបបង្កើតថ្មីត្រូវជូនដំណឹង មិនឱ្យហួស ១៨០ ថ្ងៃ គិតចាប់ពីថ្ងៃចុះបញ្ជីពន្ធដារជាស្ថាពររួច<br>– ឯកសារគាំទ្រដល់កិច្ចបញ្ជីការគណនេយ្យ ត្រូវជាភាសាខ្មែរ ឬ អាចប្រើភាសាអង់គ្លេសអមជាមួយភាសាខ្មែរបាន => សម្រាប់ឯកសារ គណនេយ្យផ្ទៃក្នុង<br>– អាចជាភាសាអង់គ្លេស => សម្រាប់ ឯកសារគណនេយ្យដែលបង្កើតចេញដោយប្រព័ន្ធកុំព្យូទ័រដែលមិនអាចប្រើជាភាសាខ្មែរបាន<br>– ឯកសារផ្តល់ដោយដៃគូធុរកិច្ចបរទេស ឬ សម្រាប់ធុរកិច្ចជាមួយដៃគូបរទេស ។<br>– ចំពោះឯកសារគាំទ្រការធ្វើធុរកិច្ច ឬប្រតិបត្តិការក្រៅពីភាសាខ្មែរ និងភាសាអង់គ្លេសត្រូវ បកប្រែឯកសារទាំងនោះជាភាសាខ្មែរឬភាសាអង់គ្លេស។<br>**១. ៣. រូបិយបណ្ណ**<br>– អាចជ្រើសរើស រូបិយបណ្ណមុខងារអាចជាប្រាក់រៀល ឬ រូបិយបណ្ណបរទេសតាមគោលនយោបាយគណនេយ្យរបស់ខ្លួន។<br>**១.៤. ការិយបរិច្ឆេទគណនេយ្យ៖**<br>– រយៈពេល ១២ ខែ គិតចាប់ពី ថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដដែល<br>– សហគ្រាសថ្មី ( គិតចាប់ផ្តើមពីថ្ងៃបង្កើតសហគ្រាស ដល់ថ្ងៃទី៣១ ខែ ធ្នូ នៃឆ្នាំដដែល) | | |
| **២. កាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុ**<br>**២.១ ស្តង់ដាគណនេយ្យ៖**<br>– សហគ្រាសទទួលខុសត្រូវជាសាធារណៈ ត្រូវប្រើស្តង់ដា គណនេយ្យ CIFRS<br>(ឧ. ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ, ធនាគារពាណិជ្ជ ឬគ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ) | **មាត្រា ១១ ,១៦ ១៧,១៨,១៩,២០,២៣** | • ព្រះរាជក្រមលេខ នស/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម |

| | | |
|---|---|---|
| – សហគ្រាសមិនទទួលខុសត្រូវជាសាធារណៈ អាចប្រើស្តង់ដាគណនេយ្យ CIFRS ឬ CIFRS for SMES<br>– អង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវប្រើប្រាស់ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ CFRS For NFPEs<br>**២.២ ភាសាសម្រាប់របាយការណ៍ហិរញ្ញវត្ថុ**<br>– ភាសា៖ ត្រូវតែជាភាសាខ្មែរ។<br>– រូបិយបណ្ណ៖ ត្រូវតែជាប្រាក់រៀល ឬ(រៀល+រូបិយបណ្ណបរទេស)<br><br>❖ **រក្សាទុកក្នុងរយៈពេលយ៉ាងតិច ១០(ដប់) ឆ្នាំ គិតពីកាលបរិច្ឆេទនៃការបង្កើតឯកសារធ្វើជាមូលដ្ឋានសម្រាប់បំពេញកាតព្វកិច្ចសារពើពន្ធ ។** | ប្រកាសលេខ ៣៣៥<br><br><br><br><br><br><br><br><br><br><br>ប្រកាសលេខ ០១១ | • ប្រកាសលេខ ៣៣៥ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១៨ ស្តីពីការដាក់ឲ្យអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ<br>• គំរូរបាយការណ៍សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ (CFRS for NFPEs) (Excel File)<br>• ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ CFRS For NFPEs<br>• ប្រកាសលេខ ០១១ អ.ស.ហ.ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ ស្តីពី "ការស្នើសុំប្រើប្រាស់ការិយបរិច្ឆេទគណនេយ្យពិសេស" |
| **៣. កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ**<br>**៣.១ សហគ្រាសជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យដោយស្វ័យប្រវត្តិ៖**<br>– សហគ្រាសសាធារណៈ<br>– សហគ្រាសទទួលខុសត្រូវជាសាធារណៈ<br>– គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP)<br>**ការអនុវត្តតាមលក្ខខណ្ឌ**<br>**សហគ្រាសជាប់លក្ខណៈវិនិច្ឆ័យ២យ៉ាងតិចក្នុងចំណោម៣ ខាងក្រោម៖** | មាត្រា២៤,២៥,២៦<br><br><br><br>ប្រកាស លេខ ៥៦៣ | • ព្រះរាជក្រមលេខ នស/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម<br>• ប្រកាស លេខ ៥៦៣ សហវ.ប្រក ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ចេញ ១០ កក្កដា ២០២០។ |

| | | |
|---|---|---|
| – ផលរបរចាប់ពី ៤ ប៊ីលានរៀល<br>– តម្លៃទ្រព្យសកម្មចាប់ពី ៣ ប៊ីលានរៀល ឡើងទៅ<br>– ចំនួនកម្មករនិយោជិតចាប់ពី ១០០ នាក់ ឡើងទៅ<br>**៣.២ អង្គភាពមិនស្វែងរកប្រាក់ចំណេញរងសវនកម្មឯករាជ្យ ស្ថិតក្នុងលក្ខណវិនិច្ឆ័យទាំងពីរខាងក្រោម៖**<br>– ចំណាយសរុបប្រចាំឆ្នាំ លើសពី ២ ០០០ ០០០ ០០០ រៀល និង<br>– ចំនួនកម្មករនិយោជិត ២០ នាក់ឡើងទៅ | សេចក្តីណែនាំលេខ ០៦៥ | • សេចក្តីណែនាំលេខ ០៦៥ ន.គ.ស/សណន ចុះថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ២០២២ ស្តីពី សំណុំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំសម្រាប់អង្គភាបមិនស្វែងរកប្រាក់ចំណេញដែលមិនជាប់កាតព្វកិច្ចរងសវនកម្មឯករាជ្យ |
| **៤. កាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ**<br>សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក ន.គ.ស. តាមលក្ខខណ្ឌដូចខាងក្រោម៖<br>**៤.១. ករណីជាប់លក្ខខណ្ឌក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ**<br>– កាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុងសវនកម្មឯករាជ្យរួចមក ន.គ.ស. មិនឱ្យហួសរយៈពេល ៦ខែ ១៥ ថ្ងៃគិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ ។<br>**៤.២. ករណីមិនជាប់លក្ខខណ្ឌក្នុងការដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំឱ្យរងសវនកម្មឯករាជ្យ**<br>– មានកាតព្វកិច្ចដាក់បញ្ជូនរបាយការណ៍ប្រចាំឆ្នាំមក ន.គ.ស. មិនឱ្យហួសរយៈពេល ៣ខែ ១៥ ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។ | ប្រកាស លេខ ៥៦៣<br><br>ស.ជ.ណ លេខ០៦៥ | • ប្រកាស លេខ ៥៦៣ សហវ.ប្រក ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ចេញ ១០ កក្កដា ២០២០។<br><br>• សេចក្តីជូនដំណឹង ស្តីពី កាតព្វកិច្ចនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ មកនិយ័តករគណនេយ្យនិងសវនកម្ម ចុះថ្ងៃទី ២៥ ខែ ធ្នូ គ. ស. ២០២៤<br>• សេចក្តីជូនដំណឹង ស្តីពីបច្ចុប្បន្នភាពនៃបញ្ជីក្រុមហ៊ុនដែលទទួលបាននីតិសម្បទាផ្តល់សេវាវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម គិតត្រឹមថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០២៤ |

| | | |
|---|---|---|
| **៤.៣. សេវាសាធារណៈរបស់និយ័តករគណនេយ្យ និងសវនកម្ម**<br><br>- ប្រកាសនេះកំណត់អំពីប្រភេទ និងកម្រៃសេវាសាធារណៈ បែបបទ នីតិវិធី និងការចាត់ចែងចំណូលពីសេវាសាធារណៈរបស់និយ័តករគណនេយ្យ និងសវនកម្ម(ន.គ.ស)។<br><br>**៤.៤. អត្រាប្តូរប្រាក់**<br><br>-សម្រាប់ប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ឆ្នាំ២០២៤។ | ប្រកាសលេខ ០០២ អ សហប្រក | **ប្រកាសស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យ និងសវនកម្ម ចុះថ្ងៃទី ១៥ មករា ឆ្នាំ ២០២៥**<br><br>**សេចក្តីជូនដំណឹង ស្តីពីអត្រាប្តូរប្រាក់ សម្រាប់ប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឆ្នាំ ២០២៤** |
| **៥. ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ**<br>– អំពីប្រព័ន្ធ: E-Filling System សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញមានមុខងារធំៗចំនួន០៣(បី) គឺ:<br>១- មុខងារបង្កើតគណនីប្រើប្រាស់(Registration Module)<br>២- មុខងារស្នើរសុំលេខអតសញ្ញាណកម្ម(Requesting Module)<br>៣- មុខងារដាក់របាយការណ៍ហិរញ្ញវត្ថុ(Submitting FS Module) | | **សៀវភៅណែនាំអំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ** |
| **៦. ពិន័យអន្តរការណ៍**<br>**ពិន័យអន្តរការណ៍ទៅតាមអំពើល្មើស ដូចខាងក្រោម៖**<br>– ក. ការប្រើការិយបរិច្ឆេទ គណនេយ្យខុសពីច្បាប់ស្តីពី គណនេយ្យ និងសវនកម្ម ដោយគ្មានការអនុញ្ញាត<br>– ខ. ការមិនប្រើភាសាខ្មែរនៅក្នុង បញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ | មាត្រា ៣២ / អនុក្រឹត្យ លេខ ៧៩ | • **ព្រះរាជក្រមលេខ នស/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម** |

| | | |
|---|---|---|
| – គ. ការប្រើប្រាស់បញ្ញើបណ្ណនៅក្នុងបញ្ជី គណនេយ្យ និង របាយការណ៍ហិរញ្ញវត្ថុ ក្រៅពីប្រាក់ រៀល ដោយគ្មានការអនុញ្ញាត | | • អនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ១ ខែមិថុនា ឆ្នាំ២០២០ ស្តីពី ពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់គណនេយ្យ និងសវនកម្ម<br><br>• ប្រព័ន្ធដាក់របាយការណ៍ហិរញ្ញវត្ថុតាមអនឡាញ (E-Filing) |
| **៧. ស្នើសុំបិទអង្គភាព :** បញ្ជាក់តម្រូវការឯកសារដែលបង្ហាញនេះផ្អែកលើបទពិសោធន៍ដែលធ្លាប់ស្នើសុំបិទអង្គភាព មិនមែនជាតារាងតម្រូវការពី ACAR ទេ។ | | • ១. លិខិតស្នើសុំរដ្ឋបាល<br>• ២. លិខិតលុបឈ្មោះពីក្រសួងមហាផ្ទៃ<br>• ៣. វិញ្ញាបនបត្រលេខ FIN<br>• ៤. លិខិតប្រគល់សិទ្ធ ឬអត្តសញ្ញាណប័ណ្ណ អ្នកយកលិខិតមកដាក់<br>• ៥.បង្កាន់ដៃបង់ប្រាក់ ឆ្នាំដាក់របាយការណ៍ទាំងអស់<br>• ៦.លិខិតលុបឈ្មោះពីពន្ធដារ<br>• ៧.Bank slip from bank<br>• ៨. Screenshot from E- filing<br>• ៩. លិខិតចុះឈ្មោះក្រសួងមហាផ្ទៃ<br>• ១០.លិខិតប្រកាសពន្ធ<br>• ១១. លក្ខន្តិកអង្គការ<br>• ១២.វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ |

| | | |
|---|---|---|
| | | • ១៣. របាយការណ៍ហិរញ្ញវត្ថុឆ្នាំចុងក្រោយ (របាយការណ៍ក្រុមប្រឹក្សាភិបាល+របាយការណ៍ហិរញ្ញវត្ថុ) |